## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តឧត្តរមានជ័យ**

សំណុំរឿងរដ្ឋប្បវេណីលេខ ០៧៧

ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ ២០២២

សាលក្រមរដ្ឋប្បវេណី

លេខ ០៣ "ខ"/១១

ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២៣

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តឧត្តរមានជ័យ

បានបើកនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី១១ ខែមករា ឆ្នាំ២០២៣ វេលាម៉ោង ១០ និង ១៩ នាទី ព្រឹក ដោយមានសមាសភាពដូចតទៅ៖

**ចៅក្រម**

លោក [redacted] អនុប្រធានសាលាដំបូងខេត្តឧត្តរមានជ័យ

**ក្រឡាបញ្ជី**

លោកស្រី [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តឧត្តរមានជ័យ

**មេធាវី**

លោក [redacted] មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទឈ្មោះ [redacted] សារុន

លោក [redacted] និងលោក [redacted] មេធាវីតំណាងដោយអាណត្តិឱ្យសហចុងចម្លើយឈ្មោះ [redacted]ឡុត និងប្រពន្ធឈ្មោះ [redacted] សារ៉ាន់

-ដើមចោទឈ្មោះ [redacted] សារុន ភេទស្រី អាយុ៧២ឆ្នាំ មុខរសមាជិកក្រុមប្រឹក្សាខេត្ត ជនជាតិខ្មែរ សញ្ជាតិខ្មែរ អាសយដ្ឋានបច្ចុប្បន្នស្ថិតនៅ [redacted]។ ទូរស័ព្ទលេខ ០១១ ៧០ ២១ ៧៨។ លោកមេធាវី [redacted] អត្តលេខ ១០២៧ ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា មានការិយាល័យក្រុមមេធាវី [redacted] មានទីតាំងស្ថិតនៅផ្ទះ [redacted]។

-សហចុងចម្លើយ ឈ្មោះ [redacted]ឡុត ភេទប្រុស អាយុ៥២ឆ្នាំ និងប្រពន្ធឈ្មោះ [redacted] សារ៉ាន់ មុខរបរអាជីវករ ជនជាតិខ្មែរ សញ្ជាតិខ្មែរ អាសយដ្ឋានបច្ចុប្បន្នស្ថិតនៅ [redacted] មានមេធាវីតំណាងដោយអាណត្តិ លោក លោកមេធាវី [redacted] អត្តលេខ ៥៦១ ជាសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា មានការិយាល័យ ក្រុមមេធាវី [redacted] និងលោក [redacted] អត្តលេខ២៦០៦T ជាសមាជិកគណមេធាវីនៃព្រះរាជាណាចក្រកម្ពុជា មានអាសយដ្ឋាន [redacted] ទូរស័ព្ទលេខ ០៧១ ៧៤ ៦០ ៧៧៧/០១២ ២៥ ៥៣ ៤៣ ។

## អង្គហេតុ និង ចំណុចវិវាទ

### ១.ការទាមទាររបស់ដើមចោទ៖

១.១.ប្តឹងសុំទាមទារប្រាក់ចំនួន ២០.០០០ (ពីរម៉ឺន) ដុល្លារអាមេរិក និងការប្រាក់ ១៨% ក្នុង១ ឆ្នាំ ពីសហចុងចម្លើយ។



Scanned with CamScanner

១.២.ប្តឹងទាមទារសំណងជម្ងឺចិត្ត និងការខាតបង់ពេលវេលាពីសហចុងចម្លើយ ១៥ ,000,000 (ដប់ប្រាំលាន) រៀល ពីសហចុងចម្លើយ។

១.៣.ប្តឹងសុំឱ្យសហចុងចម្លើយជាអ្នកទទួលបន្ទុក និងរ៉ាប់រងលើប្រាក់ប្រដាប់ក្តី។

១.៤.បង្គាប់ឱ្យសហដើមចោទនៃបណ្តឹងតបសងប្រាក់ចំនួន ១២,៦៧៥ $ (មួយម៉ឺនពីរពាន់ប្រាំមួយរយចិតសិបប្រាំ) ដុល្លារអាមេរិក ទៅឱ្យសហចុងចម្លើយនៃបណ្តឹងតប។

១.៥.បង្គាប់ឱ្យសហចុងចម្លើយនៃបណ្តឹងតបសងប្រាក់ថ្លៃខូចខាតចំនួន ៥000 (ប្រាំពាន់) បាតថៃ ក្នុងមួយថ្ងៃលើការរឹបអូសយក អាប៊ុលសាស័រ ពណ៌លឿង ១គ្រឿង ម៉ាក KOMATSU SD25 ចាប់ពីថ្ងៃទី០២ ខែសីហា ឆ្នាំ២០២២ រហូតដល់ថ្ងៃប្រគល់អាប៊ុលសាស័រ វិញ ទៅឱ្យសហដើមចោទនៃបណ្តឹងតប។

១.៦.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់សចុងចម្លើយនៃបណ្តឹងតប។

## ២.ការពន្យល់ត្រួសៗអំពីរឿងក្តី

កាលពីថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០២២ សហកូនបំណុលទាំងពីរនាក់ប្តីប្រពន្ធឈ្មោះ [redacted] ឡុត ភេទប្រុស អាយុ៥២ឆ្នាំ និងប្រពន្ធឈ្មោះ [redacted] សារ៉ាន់ ភេទស្រី អាយុ៤៣ឆ្នាំ បានខ្ចីប្រាក់ពីដើមចោទចំនួន ៥000 (ប្រាំពាន់) ដុល្លារអាមេរិក និងបានធ្វើកិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០២២ ដោយបានសន្យាឱ្យការប្រាក់មកនាងខ្លួនក្នុងមួយខែពីររយហាសិបដុល្លាអាមេរិក លុះក្រោយមកនៅថ្ងៃទី៣0 ខែឧសភា ឆ្នាំ២០២២ សហកូនបំណុលក៏បានមកខ្ចីប្រាក់ពីដើមចោទបន្ថែមចំនួន ១៥.000 (មួយម៉ឺនប្រាំពាន់)ដុល្លាអាមេរិកទៀត និងបានធ្វើកិច្ចសន្យាដូចគ្នា ។ ប៉ុន្តែចាប់តាំងពីខ្ចីមកសហចុងចម្លើយមិនដែលបានបង់ការប្រាក់ឱ្យមកដើមចោទនោះទេ។ ពេលខ្ចីសន្យាថា ខ្ចីក្នុងរយៈពេលខ្ចីប៉ុណ្ណោះហើយនៅក្នុងកិច្ចសន្យា គឺបញ្ជាក់ថា បើម្ចាស់លុយត្រូវការ គឺត្រូវប្រាប់ក្នុងរយៈពេលមួយខែមុន ពេលដែលដើមចោទប្រាប់ថាត្រូវការប្រាក់វិញហើយ ក៏សហចុងចម្លើយនៅតែមិនព្រមប្រគល់ ឬបង់ការប្រាក់ឱ្យមកដើមចោទនោះទេ ។ មិនតែប៉ុណ្ណោះនៅប្រើពាក្យមិនសមរម្យ មកលើដើមចោទជាម្ចាស់ប្រាក់ទៀតផង ពេលដែលទៅទារចុងចម្លើយចេះតគេចវេសមិនព្រមសង ដោយសន្យាថាថ្ងៃនេះថ្ងៃនោះ ដោយឃើញសកម្មភាពរបស់សហចុងចម្លើយបែបនេះយើងខ្លួនខ្លាចមានការបាត់បង់ផលប្រយោជន៍ ទើបដើមចោទសម្រេចចិត្តដាក់ពាក្យបណ្តឹងទាមទារប្រាក់ពីសហចុងចម្លើយឈ្មោះ [redacted] ឡុត ភេទប្រុស អាយុ៥២ឆ្នាំ និងប្រពន្ធឈ្មោះ [redacted] សារ៉ាន់ ភេទស្រី អាយុ៤៣ឆ្នាំ ។

## ៣.ចំណុចវិវាទ

១.តើសហចុងចម្លើយបានសងប្រាក់ឱ្យទៅដើមចោទហើយឬនៅ?

២.តើទំនាក់ទំនងកិច្ចសន្យាទាំង០៥កន្លងមក មានទំនាក់ទំនងគតិយុត្តជាមួយដើមចោទ ដែរឬទេ?

៣.តើសហចុងចម្លើយបានសងប្រាក់ឱ្យទៅដើមចោទហើយឬនៅ?

៤.តើការសម្រេចរក្សាការពាររឹបអូស អាប៊ុលសាស័រ ពណ៌លឿង ០១គ្រឿងម៉ាក KOMATSU SD25 នាំឱ្យមានការខូចខាតដល់សហដើមចោទនៃបណ្តឹងតបដែរឬទេ?

## ៤.សេចក្តីថ្លែងការរបស់គាគី

+លោកមេធាវី [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទឈ្មោះ [redacted] សារុន ភេទស្រី អាយុ៧២ឆ្នាំ បានថ្លែងការណ៍ថា ខ្លួនសុំរក្សាការទាមទារនៅដដែល ដោយហេតុថា៖



Scanned with CamScanner

១-សហចុងចម្លើយឈ្មោះ [redacted] ឡុត ភេទប្រុស អាយុ ៥២ ឆ្នាំ និងប្រពន្ធឈ្មោះ [redacted] សាវ៉ាន់ អាយុ ៤៣ ឆ្នាំ រស់នៅ [redacted] គឺជាអ្នកស្គាល់គ្នាយូរណាស់មកហើយរហូតក្លាយជាមិត្តភ័ក្តិនឹងគ្នាជាមួយឈ្មោះ [redacted] ស៊ីណាត ភេទប្រុស អាយុ ៥២ ឆ្នាំ បច្ចុប្បន្នរស់នៅ [redacted]។ ឈ្មោះ [redacted] ស៊ីណាត ជាកូនប្រុសបង្កើតរបស់ដើមចោទឈ្មោះ [redacted] សារុន ភេទស្រី ហើយជាឪពុកបង្កើតរបស់ឈ្មោះ [redacted] លីហេង ភេទប្រុស អាយុ ២៤ ឆ្នាំ ហើយក៏ជាអ្នករស់នៅ [redacted] ងដែរ។

២-ដំបូងឡើយសហចុងចម្លើយ បានទំនាក់ទំនងជាមួយឈ្មោះ [redacted] ស៊ីណាត ដើម្បីរកខ្ចីប្រាក់។ ដោយសារខ្លួនជាទាហាន មិនសូវបានរស់នៅជាប់លាប់ក្នុងក្រុងសំរោង ខេត្តឧត្តរមានជ័យ ឈ្មោះ [redacted] ស៊ីណាត បានឱ្យកូនប្រុសខ្លួនឈ្មោះ [redacted] លីហេង ជាអ្នកដើរតួរជាម្ចាស់បំណុលជំនួសខ្លួន ហើយបានប្រគល់ប្រាក់របស់ខ្លួនទៅឱ្យកូនប្រុស ដើម្បីចាត់ចែងឱ្យសហកូនបំណុលឈ្មោះ [redacted] ឡុត និងប្រពន្ធឈ្មោះ [redacted] សាវ៉ាន់ ខី ដោយបានធ្វើកិច្ចសន្យាខ្ចីប្រាក់ចំនួន ០៥ កិច្ចសន្យា។

៣-កិច្ចសន្យាខ្ចីប្រាក់ចំនួន ០៤ គឺធ្វើឡើងរវាងឈ្មោះ [redacted] លីហេង ជាម្ចាស់បំណុល និងឈ្មោះ [redacted] ឡុត និងប្រពន្ធឈ្មោះ [redacted] សាវ៉ាន់ ជាសហកូនបំណុល ហើយមានកិច្ចសន្យាតែមួយគត់ ដែលបានធ្វើឡើងរវាងឈ្មោះ [redacted] ស៊ីណាត ជាម្ចាស់បំណុល និងឈ្មោះ [redacted] ឡុត និងប្រពន្ធឈ្មោះ [redacted] សាវ៉ាន់ ជា សហកូនបំណុល កិច្ចសន្យាទាំង ៥ មានដូចខាងក្រោម៖

៣.១-កិច្ចសន្យាចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០២១ រវាងឈ្មោះ [redacted] ស៊ីណាត ជាម្ចាស់បំណុល និងឈ្មោះ [redacted] ឡុត និងប្រពន្ធឈ្មោះ [redacted] សាវ៉ាន់ ជាសហកូនបំណុល ប្រាក់កម្ចីចំនួន ១០,០០០ (មួយម៉ឺន) ដុល្លារអាមេរិក បានសងប្រាក់ដើមចំនួនត្រឹមតែ ៥,០០០ (ប្រាំពាន់) ដុល្លារអាមេរិក មិនចាំថ្ងៃសងតែមានសំណេរលើកិច្ចសន្យាបញ្ជាក់ពីចំនួនប្រាក់សង។

៣.២-កិច្ចសន្យាចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២១ រវាងឈ្មោះ [redacted] លីហេង ជាម្ចាស់បំណុល និងឈ្មោះ [redacted] ឡុត និងប្រពន្ធឈ្មោះ [redacted] សាវ៉ាន់ ជាសហកូនបំណុល ប្រាក់កម្ចីចំនួន ២០.០០០,០០០ (ម្ភៃលាន) រៀល ស្មើនឹង ៥,០០០ (ប្រាំពាន់) ដុល្លារអាមេរិក បានសងប្រាក់ដើមគ្រប់ចំនួននៅថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២២។

៣.៣-កិច្ចសន្យាចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២១ រវាងឈ្មោះ [redacted] លីហេង ជាម្ចាស់បំណុល និងឈ្មោះ [redacted] ឡុត និងប្រពន្ធឈ្មោះ [redacted] សាវ៉ាន់ ជាសហកូនបំណុល ប្រាក់កម្ចីចំនួន ៥,០០០ (ប្រាំពាន់) ដុល្លារអាមេរិក មិនទាន់បានសងប្រាក់ដើមទេ។

៣.៤-កិច្ចសន្យាចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២១ រវាងឈ្មោះ [redacted] លីហេង ជាម្ចាស់បំណុល និងឈ្មោះ [redacted] ឡុត និងប្រពន្ធឈ្មោះ [redacted] សាវ៉ាន់ ជាសហកូនបំណុល ប្រាក់កម្ចីចំនួន ៥,០០០ (ប្រាំពាន់) ដុល្លារអាមេរិក មិនទាន់បានសងប្រាក់ដើមទេ ដើមចោទឈ្មោះ [redacted] សារុន ភេទស្រី បានផ្តិតស្នាមមេដៃជាសាក្សី។

៣.៥-កិច្ចសន្យាចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០២២ រវាងឈ្មោះ [redacted] លីហេង ជាម្ចាស់បំណុល និងឈ្មោះ [redacted] ឡុត និងប្រពន្ធឈ្មោះ [redacted] សាវ៉ាន់ ជាសហកូនបំណុល ប្រាក់កម្ចីចំនួន ១០,០ ០០ (មួយម៉ឺន) ដុល្លារអាមេរិក ដើមចោទឈ្មោះ [redacted] សារុន ភេទស្រី បានផ្តិតស្នាមមេដៃជាសាក្សី បានសងប្រាក់ដើមចំនួនត្រឹមតែ ៥,០០០ (ប្រាំពាន់) ដុល្លារអាមេរិក សងនៅថ្ងៃទី២៨ ខែមេសា ឆ្នាំ២០២២ មិនមែនសងក្នុងខែឧសភា ដូចក្នុងឯកសារចម្លើយរបស់សហចុងចម្លើយនោះទេ។



Scanned with CamScanner

៤-កិច្ចសន្យាខ្ចីប្រាក់ទាំងអស់ចំនួន ០៥ ខាងលើ មានប្រាក់កម្ចីគិតជាប្រាក់ដុល្លារសរុប ៣៥,០០០ (បីម៉ឺនប្រាំពាន់) ដុល្លារអាមេរិក ដែលសហចុងចម្លើយបានខ្ចីពីឈ្មោះ [redacted] ស៊ីណាត និងកូនប្រុសរបស់គាត់ឈ្មោះ [redacted] លីហេង ហើយសហចុងចម្លើយបានសងប្រាក់ដើម គិតជាប្រាក់ដុល្លារសរុបត្រឹមតែ ១៥,០ ០០ (មួយម៉ឺនប្រាំពាន់) ដុល្លារអាមេរិក ដូចបញ្ជាក់ក្នុងកិច្ចសន្យានីមួយៗ។ ដូច្នេះផ្អែកតាមការកាត់កងគ្នាខាងលើ សហចុងចម្លើយនៅជំពាក់ប្រាក់ដើមឈ្មោះ [redacted] ស៊ីណាត និងឈ្មោះ [redacted] លីហេង ដែលជាសហម្ចាស់បំណុលចំនួន ២០.០០០ (ពីរម៉ឺន) ដុល្លារអាមេរិកគត់។

៥-បន្ទាប់មកឈ្មោះ [redacted] ស៊ីណាត មានផែនការទិញឡានម៉ាក TUNDRA សេរីឆ្នាំ២០០៨ ខ្វះប្រាក់ទិញឡាន ក៏សុំឱ្យសហចុងចម្លើយសងប្រាក់នៅជំពាក់ទាំងអស់ចំនួន ២០.០០០ (ពីរម៉ឺន) ដុល្លារអាមេរិកទៅឱ្យគាត់ និងកូនប្រុសឈ្មោះ [redacted] លីហេង វិញ ប៉ុន្តែសហចុងចម្លើយមិនទាន់អាចមានលទ្ធភាពសងបាន ក៏ឈ្មោះ [redacted] ស៊ីណាត បានខ្ចីប្រាក់ពីដើមចោទឈ្មោះ [redacted] សាវុន ភេទស្រី ជាម្តាយបង្កើតរបស់ខ្លួនចំនួន ២០.០០០ (ពីរម៉ឺន) ដុល្លារអាមេរិក ដើម្បីយកមកបង្គ្រប់ទិញឡាន។

៦-ក្រោយពីមានការពិភាក្សាគ្នា លើការកាត់កងប្រាក់កម្ចីរវាងឈ្មោះ [redacted] លីហេង ព្រមទាំងសហចុងចម្លើយឈ្មោះ [redacted] ឡុត និងប្រពន្ធឈ្មោះគ្នា ដោយឱ្យសហចុងចម្លើយទទួលស្គាល់ថា ប្រាក់នៅជំពាក់ឈ្មោះ [redacted] ស៊ីណាត និងកូនប្រុសឈ្មោះ [redacted] សាវ៉ាន់ ក៏ឈានដល់ចំណុចឯកភាព [redacted] ស៊ីណាត និងកូនឈ្មោះ [redacted] លីហេង ចំនួន ២០.០០០ (ពីរម៉ឺន) ដុល្លារអាមេរិក ត្រូវកាត់កងទៅជាប្រាក់ ដែលសហចុងចម្លើយបានខ្ចី និងនៅជំពាក់ដើមចោទឈ្មោះ [redacted] សាវុន ភេទស្រី វិញ ដោយសារឈ្មោះ [redacted] ស៊ីណាត បានខ្ចីប្រាក់ចំនួន ២០.០០០ (ពីរម៉ឺន) ដុល្លារអាមេរិកពីដើមចោទជាម្តាយបង្កើតបង្គ្រប់ទិញឡាន ហើយចាប់ពីពេលនោះមក កាតព្វកិច្ចរបស់សហចុងចម្លើយជាមួយឈ្មោះ [redacted] ស៊ីណាត និងឈ្មោះ [redacted] លីហេង ដែលជាអតីតសហម្ចាស់បំណុលក្នុងកិច្ចសន្យាទាំង០៥ ខាងលើត្រូវបានរលត់។

៧-ដោយមានការយល់ព្រមពីសហចុងចម្លើយឈ្មោះ [redacted] ឡុត និងប្រពន្ធឈ្មោះ [redacted] សាវ៉ាន់ ព្រមទាំងមានការយល់ព្រមពីដើមចោទឈ្មោះ [redacted] សាវុន ភេទស្រីផង ភាគីទាំងពីរក៏បានចុះកិច្ចសន្យាថ្មីចំនួន ០២ ដាក់បញ្ចូលប្រាក់ចំនួនសរុប ២០.០០០ (ពីរម៉ឺន) ដុល្លារអាមេរិក ដែលសហចុងចម្លើយបានទទួលស្គាល់ជាប្រាក់ ដែលខ្លួនបានខ្ចី និងនៅជំពាក់ដើមចោទឈ្មោះ [redacted] សាវុន ភេទស្រី វិញ ហើយភាគីទាំងពីរបានផ្តិតស្នាមមេដៃស្តាំលើកិច្ចសន្យាទាំងពីរដូចខាងក្រោម៖

៧.១-កិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០២២ រវាងដើមចោទឈ្មោះ [redacted] សាវុន ភេទស្រី ជាម្ចាស់បំណុល និងសហចុងចម្លើយឈ្មោះ [redacted] ឡុត ភេទប្រុស និងប្រពន្ធឈ្មោះ [redacted] សាវ៉ាន់ ជាសហកូនបំណុលប្រាក់កម្ចីចំនួន ៥,០០០ (ប្រាំពាន់) ដុល្លារអាមេរិក អត្រាការប្រាក់ ២៥០ (ពីររយហាសិប) ដុល្លារអាមេរិកក្នុង ១ខែ គ្មានទ្រព្យដាក់ធានាសិទ្ធិលើបំណុល ហើយកិច្ចសន្យាបញ្ជាក់ថា៖ បើម្ចាស់លុយត្រូវការលុយត្រឡប់មកវិញ ត្រូវប្រាប់កូនបំណុលមុនរយៈពេលមួយខែ។

៧.២-កិច្ចសន្យាចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២២ រវាងដើមចោទឈ្មោះ [redacted] សាវុន ភេទស្រី ជាម្ចាស់បំណុល និងសហចុងចម្លើយឈ្មោះ [redacted] ឡុត ភេទប្រុស និងប្រពន្ធឈ្មោះ [redacted] សាវ៉ាន់ ជាសហកូនបំណុល ប្រាក់កម្ចីចំនួន ១៥,០០០ (មួយម៉ឺនប្រាំពាន់) ដុល្លារអាមេរិក អត្រាការប្រាក់ ៩០០ (ប្រាំបួនរយ) ដុល្លារអាមេរិកក្នុង ១ខែ គ្មានទ្រព្យដាក់ធានាសិទ្ធិលើបំណុល ហើយកិច្ចសន្យាបញ្ជាក់ថា៖ បើម្ចាស់លុយត្រូវការលុយត្រឡប់មកវិញ ត្រូវប្រាប់កូនបំណុលមុនរយៈពេលមួយខែ។



Scanned with CamScanner

៨-កិច្ចសន្យាទាំងពីរបានសរសេ និងចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០២២ និងចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២២ តែភាគីទាំងពីរមិនទាន់បានផ្តិតស្នាមមេដៃនៅឡើយទេ រហូតទាល់តែសហចុងចម្លើយបានសងប្រាក់ដើម២០.០០០,០០០ (ម្ភៃលាន) រៀលទៅឱ្យម្ចាស់បំណុលឈ្មោះ [redacted] លីហេង នៅថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២២តាមកិច្ចសន្យាចាស់ចុះថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ២០២១ ទើបភាគីទាំងពីរផ្តិតស្នាមមេដៃស្តាំលើកិច្ចសន្យាជាក្រោយ។

៩-ចាប់តាំងពីបានខ្ចីប្រាក់ផ្អែកតាមកិច្ចសន្យាទាំងពីរខាងលើ សហចុងចម្លើយមិនដែលបានបង់ការប្រាក់ ឬសងប្រាក់ដើមមកឱ្យដើមចោទនោះទេ ហើយពេលដែលដើមចោទតែងតែទាក់ទងតាមទូរស័ព្ទទារប្រាក់ សហចុងចម្លើយមិនលើកទូរស័ព្ទ ពេលខ្លះលើកបាននិយាយថា ចាំពេលនេះសង ពេលនោះសង តែមិនឃើញសងលុយមកដើមចោទ ទាំងប្រាក់ដើមទាំងប្រាក់ការ គឺមិនទាន់បានសងអ្វីទាំងអស់ ចេះតែគេចវេសមិនព្រមសង។

១០-ដើមចោទបានធ្វើពាក្យបណ្តឹងនៅថ្ងៃទី០៤ ខែសីហា ឆ្នាំ២០២២ និងបានដាក់ចូលសាលាដំបូងខេត្តឧត្តរមានជ័យនៅថ្ងៃទី០៩ ខែសីហា ឆ្នាំ២០២២ សុំឱ្យតុលាការចេញសាលក្រម ដែលមានខ្លឹមសារ៖

១០.១-ប្តឹងសុំទាមទារប្រាក់ដើមចំនួន ២០.០០០ (ពីរម៉ឺន) ដុល្លារអាមេរិក និងការប្រាក់ ១៨% ក្នុងមួយឆ្នាំពីសហចុងចម្លើយ។

១០.២-ប្តឹងទាមទារសំណងជម្ងឺចិត្ត និងការខាតបង់ពេលវេលាចំនួន ១៥,០០០,០០០ (ដប់ប្រាំលាន)រៀលពីសហចុងចម្លើយ។

១០.៣-ប្តឹងសុំឱ្យសហចុងចម្លើយជាអ្នកទទួលបន្ទុក និងរ៉ាប់រងលើប្រាក់ប្រដាប់ក្តីផ្សេងៗ។

១១-ការអះអាងរបស់សហចុងចម្លើយ ដែលថាបានសងប្រាក់ដើមចំនួន ៥,០០០ (ប្រាំពាន់) ដុល្លារអាមេរិកនៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០២២ តាមពិតក្នុងខែមេសាទេ ផ្អែកលើកំណត់ហេតុទូទាត់ប្រាក់ និងសងប្រាក់ដើមចំនួន ២០.០០០, ០០០ (ម្ភៃលាន) រៀលនៅថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០២២ ទៅឱ្យដើមចោទមិនពិតទេ ប៉ុន្តែតាមពិតសងទៅឱ្យម្ចាស់បំណុលឈ្មោះ [redacted] លីហេង ដែលកូនបំណុលខ្ចីតាមកិច្ចសន្យាចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០២២ និងកិច្ចសន្យាចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២១ ដែលកិច្ចសន្យាទាំងពីរនេះ ក្នុងចំណោមកិច្ចសន្យាចាស់ទាំង ០៥ បានអស់សុពលភាពទៅហើយ តាមរយៈការកាត់កងប្រាក់ជំពាក់គ្នា រវាងសហម្ចាស់បំណុលឈ្មោះ មូលស៊ីណាត និងឈ្មោះ [redacted] លីហេង មិនមែនសងទៅឱ្យដើមចោទឈ្មោះ [redacted] សារុន ភេទស្រី ដែលទាក់ទងនឹងកិច្ចសន្យាថ្មីចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០២២ និងកិច្ចសន្យាថ្មីចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២២ ដែលដើមចោទបានធ្វើជាមួយសហចុងចម្លើយ ពាក់ព័ន្ធនឹងប្រាក់កម្ចីចំនួន ២០.០០០ (ពីរម៉ឺន) ដុល្លារអាមេរិកនោះឡើយ។

១២-កិច្ចសន្យាចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០២២ ប្រាក់កម្ចីចំនួន ១០០០០ (មួយម៉ឺន) ដុល្លារ ទាក់ទងនឹងការសងប្រាក់ដើមចំនួនត្រឹមតែ USD៥០០០ និងកិច្ចសន្យាចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២១ ទាក់ទងនឹងការសងប្រាក់ដើមចំនួន ២០ លានរៀល កិច្ចសន្យាទាំងពីរនេះគឺបញ្ជាក់ពីឈ្មោះ [redacted] លីហេង ជាម្ចាស់បំណុល មិនមែនឈ្មោះ [redacted] សារុន ដើមចោទជាម្ចាស់បំណុលនោះទេ ដូច្នេះដើមចោទឈ្មោះ [redacted] សារុន មិនបានទទួលការសងប្រាក់ដើមពីកិច្ចសន្យាទាំងពីរនេះទេ។

១៣-ការអះអាងរបស់សហចុងចម្លើយដែលថា៖ ខ្លួនបានសងការប្រាក់ចំនួន ១១,០០០,០០០ (ដប់មួយលាន) រៀល (ចំនួនត្រឹមតែ ១០ លានរៀល មិនមែន ១១ លានរៀលនោះទេ) និង៥,៧០០ (ប្រាំពាន់ប្រាំពីររយ) ដុល្លារអាមេរិក ឥឡូវឡើងដល់ ៧,២០០ (ប្រាំពីរពាន់ពីររយ) ដុល្លារអាមេរិកទៅឱ្យដើមចោទចាប់ពីខែកក្កដា ឆ្នាំ២០២១ ដល់ខែមិថុនា



Scanned with CamScanner

ឆ្នាំ២០២២ គឺជាការប្រាក់ ដែលសហចុងចម្លើយបានទូទាត់ទៅឱ្យម្ចាស់បំណុលឈ្មោះ [redacted] លីហេង ទាក់ទងនឹងកិច្ចសន្យាចាស់ ដែលបានអស់សុពលភាពទៅហើយ ដើមចោទសុំច្រានចោលនូវការអះអាងនេះ ពីព្រោះដើមចោទមិនដែលបានទទួលការប្រាក់ និងមិនដែលបានទទួលការសងប្រាក់ដើម សូម្បីតែមួយសេនពីសហចុងចម្លើយឡើយ ចាប់តាំងពីសហចុងចម្លើយបានយល់ព្រម និងទទួលស្គាល់ប្រាក់ចំនួន ២០.០០០ (ពីរម៉ឺន) ដុល្លារ ជាប្រាក់ដែលខ្លួនបានខ្ចី និងនៅជំពាក់ដើមចោទតាមរយៈកិច្ចសន្យាចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០២២ និងកិច្ចសន្យាចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២២ ដែលជាកិច្ចសន្យាទើបតែបានធ្វើក្រោយ។

១៤-ការសងប្រាក់ដើមចំនួន ៥០០០ (ប្រាំពាន់) ដុល្លារ និងការសងប្រាក់ដើមចំនួន ២០ លានរៀលព្រមទាំងការសងការប្រាក់ចំនួន ១១,០០០,០០០ (ដប់មួយលាន) រៀល (ចំនួនត្រឹមតែ ១០ លានរៀល មិនមន១១ លានរៀលនោះទេ) និង៥,៧០០ (ប្រាំពាន់ប្រាំពីររយ) ដុល្លារអាមេរិក ឥឡូវឡើងដល់ ៧,២០០ (ប្រាំពីរពាន់ពីររយ) ដុល្លារអាមេរិក ក្នុងពាក្យសុំកែតម្រូវឯកសារចម្លើយរបស់សហចុងចម្លើយ ដើមចោទឈ្មោះ [redacted] សារុន មិនបានដឹងរឿងនេះទេ ហើយមិនដឹងថាចំនួនតួលេខនៃការប្រាក់ទាំងនេះត្រឹមត្រូវ ឬយ៉ាងណាទេ តែវាជាការទូទាត់ក្នុងកិច្ចសន្យាចាស់ ដែលអស់សុពលភាពទៅហើយ ដែលមានឈ្មោះ [redacted] ឡុត និងប្រពន្ធឈ្មោះ [redacted] សារ៉ាន់ ជាសហកូនបំណុល និងឈ្មោះ [redacted] ស៊ីណាត និងឈ្មោះ [redacted] សារុន ដើមចោទជាម្ចាស់បំណុលនោះទេ ហើយដើមចោទសុំបដិសេធនូវការអះអាងទាំងនេះ ពីព្រោះការទូទាត់ក្នុងកិច្ចសន្យាចាស់នេះ មិនមានទំនាក់ទំនងគតិយុត្តជាមួយនឹងកិច្ចសន្យាថ្មីចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០២២ និងកិច្ចសន្យាថ្មីចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២២ ឡើយ។

១៥-ដើមចោទដាក់ពាក្យបណ្ដឹងចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០២២ គឺជាការទាមទារឱ្យសហចុងចម្លើយសងប្រាក់ដើមចំនួន ២០.០០០ (ពីរម៉ឺន) ដុល្លារអាមេរិក និងសងការប្រាក់ ១៨% ក្នុងមួយឆ្នាំ ផ្អែកតែទៅលើកិច្ចសន្យាថ្មីចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០២២ និងកិច្ចសន្យាថ្មីចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២២ ប៉ុណ្ណោះ មិនពាក់ព័ន្ធនឹងកិច្ចសន្យាចាស់អស់សុពលភាព ដែលមានទំនាក់ទំនងគតិយុត្ត និងកាតព្វកិច្ចបានរលត់រវាងឈ្មោះ [redacted] ស៊ីណាត និងឈ្មោះ [redacted] លីហេង ជាអតីតម្ចាស់បំណុល និងឈ្មោះ [redacted] ឡុត និងប្រពន្ធឈ្មោះ [redacted] សារ៉ាន់ ជាអតីតសហកូនបំណុល តាមរយៈការអនុវត្តកាតព្វកិច្ចនៃការសងបំណុល និងការទូទាត់ការប្រាក់រួចរាល់នោះឡើយ ហើយកិច្ចសន្យាចាស់ក៏គ្មានទំនាក់ទំនងគតិយុត្ត និងកាតព្វកិច្ចអ្វីជាមួយដើមចោទឈ្មោះ [redacted] សារុន នោះដែរ។

១៦-ការអះអាងរបស់សហចុងចម្លើយ ដែលថាកិច្ចសន្យាចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០២២ និងកិច្ចសន្យាចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២២ មិនបានកំណត់អំពីពេលវេលានៃការសងប្រាក់ដើមនៅពេលណាជាក់លាក់ គឺមិនពិតទេ តាមពិតកិច្ចសន្យាទាំងពីរនេះ ពិតជាបានកំណត់ពេលវេលានៃការសងប្រាក់ដើម តាមលក្ខខណ្ឌក្នុងកិច្ចសន្យា ដែលបានចែងក្នុងសេចក្ដីបញ្ជាក់ថា៖ បើម្ចាស់លុយត្រូវការលុយត្រឡប់មកវិញ ត្រូវប្រាប់កូនបំណុលមុនរយៈពេល១ ខែ។ ដូច្នេះ អត្ថិភាពនៃការទាមទារសិទ្ធិលើបំណុលរបស់ដើមចោទ ពិតជាកើតមានតាមលក្ខខណ្ឌកំណត់ពេល ដែលបានចែងនៅក្នុងសេចក្ដីបញ្ជាក់នៃកិច្ចសន្យាទាំងពីរនេះ។

១៧.ការអះអាងរបស់សហចុងចម្លើយថា៖ កិច្ចសន្យាចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២២ ក៏ដូចជាកិច្ចសន្យាចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០២២ គឺជាលិខិតដែលដើមចោទបានរៀបចំ ដើម្បីបញ្ជាក់ពីប្រាក់បំណុលជាប្រាក់ដុល្លារអាមេរិក ដែលនៅសល់ចុងក្រោយ ដោយដាក់ឈ្មោះ របស់ដើមចោទវិញចំនួន ១៥,០០០ (មួយម៉ឺនប្រាំពាន់) ដុល្លារអាមេរិក



Scanned with CamScanner

ដែលសរុប ២០.០០០ (ពីរម៉ឺន) ដុល្លារអាមេរិក គឺមិនមានការប្រគល់-ទទួលប្រាក់ ខ្លួនសុំបញ្ជាក់ថា ភាគីទាំងពីរពិតជាមានការសម្តែងឆន្ទៈ ដោយគ្មានការបង្ខិតបង្ខំពីភាគីខាងណាមួយឡើយ យល់ព្រមបង្កើតកិច្ចសន្យាចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០២២ និងកិច្ចសន្យាចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២២ ទាក់ទងនឹងប្រាក់ចំនួន ២០.០០០ (ពីរម៉ឺន) ដុល្លារអាមេរិក ជាប្រាក់ដែលភាគីចុងចម្លើយនៅជំពាក់ឈ្មោះ [redacted] ស៊ីណាត ហើយបង្វែរប្រាក់នោះទៅជាប្រាក់ ដែលសហចុងចម្លើយទទួលស្គាល់ថា ខ្លួនបានខ្ចី និងនៅជំពាក់ដើមចោទឈ្មោះ [redacted] សាវុន ភេទស្រីវិញ ជំនួសឱ្យឈ្មោះ [redacted] ស៊ីណាត ដែលបានខ្ចីពីដើមចោទ ហើយភាគីទាំងពីរបានផ្តិតស្នាមមេដៃស្តាំ លើកិច្ចសន្យាទាំងពីរនេះ ស្របតាមគោលការណ៍ច្បាប់ តាមឆន្ទៈស្ម័គ្រចិត្តទាំងសងខាង ដោយគ្មានការបង្ខិតបង្ខំពីភាគីណាឡើយ។

សូមលើកឡើងអំពីផ្លូវច្បាប់ តាមមាត្រា ៣០៩ នៃក្រមរដ្ឋប្បវេណី គឺកិច្ចសន្យាបង្កើតឡើងដោយស្របតាមឆន្ទៈរបស់គូរភាគី ដោយគ្មានការបង្ខិតបង្ខំរបស់ភាគីណាមួយឡើយ និងកិច្ចសន្យាបង្កើតឡើងដោយគ្មានវិការៈ ភាគីទាំងសងខាងត្រូវធ្វើការអនុវត្តឱ្យបានត្រឹមត្រូវទៅតាមការកំណត់ដែលភាគីបានព្រមព្រៀងគ្នា។ ខ្លួនសូមរក្សាការទាមទារដូចដែលមាននៅក្នុងពាក្យបណ្តឹងដើម។ នៅក្នុងកិច្ចសន្យាចាស់ និងកិច្ចសន្យាថ្មី សហកូនបំណុលសងថ្លៃណា គឺសរសេរទូរទាត់ច្បាស់នៅក្នុងកិច្ចសន្យាចាស់ ទូរទាត់អស់សល់ជំពាក់ចំនួន ២ (ពីរ) ម៉ឺន ដុល្លារ។ ឈ្មោះ [redacted] ស៊ីណាត ជំពាក់ប្រាក់របស់ម្តាយឈ្មោះ [redacted] សាវុន អត់មានលុយសង ទើបបានធ្វើកិច្ចសន្យាថ្មី ដែលមានការទទួលស្គាល់ពីដើមចោទ និងសហចុងចម្លើយ ដោយឱ្យសហចុងចម្លើយសងប្រាក់ឱ្យទៅលោកស្រី [redacted] សាវុន វិញ តាមរយៈកិច្ចសន្យាថ្មី ដែលមានសុពលភាព។ ចំពោះកិច្ចសន្យាចាស់ គឺលែងមានអានុភាពអនុវត្តទៀតហើយ ព្រោះ ពេលនោះមានការព្រមព្រៀងគ្នារវាងម្ចាស់បំណុល និងសហកូនបំណុលរួចរាល់។ កិច្ចសន្យាគោរពឆន្ទៈរបស់គូរភាគី ដោយមានការទទួលស្គាល់ពីការផ្ទេរបំណុលពីកិច្ចសន្យាចាស់ មកកិច្ចកិច្ចសន្យាថ្មី គឺជាច្បាប់ចងភាគីទាំងសងខាងឱ្យអនុវត្តតាម។ សូមទាមទារសំណងជម្ងឺចិត្តចំនួន ១៥ លានរៀល។

+លោកមេធាវី [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយនៃបណ្តឹងតបឈ្មោះ [redacted] សាវុន ភេទស្រី អាយុ៧២ឆ្នាំ បានថ្លែងការណ៍ថា គ្រប់ពេលមានការសងលុយនៅក្នុងកិច្ចសន្យាចាស់ពិតជាមានការបញ្ជាក់ពីសហចុងចម្លើយ។ តាមទម្លាប់ខ្មែរយើង ពេលខ្ចីលុយអ្នកស្និតស្នាលពេលខ្លះមិនសូវបានធ្វើឯកសារ។ ដូច្នេះសូមបដិសេធចំពោះការទាមទារចំណុចទី០១ នៅក្នុងបណ្តឹងតប។ បណ្តឹងតបចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២២ តបទៅនឹងបណ្តឹងចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០២២ របស់ដើមចោទ (ចុងចម្លើយនៃបណ្តឹងតប) មានកម្មវត្ថុនៃបណ្តឹងតប ទាមទារឱ្យតុលាការចេញសាលក្រមដែលមានខ្លឹមសារ ១,បង្គាប់ឱ្យសហដើមចោទនៃបណ្តឹងតបសងប្រាក់ចំនួន ១២,៦៧៥$ (មួយម៉ឺនពីរពាន់ប្រាំមួយរយចិតសិប្រាំ) ដុល្លារអាមេរិក ឱ្យទៅសហចុងចម្លើយនៃបណ្តឹងតប ២, បង្គាប់ឱ្យសចុងចម្លើយនៃបណ្តឹងតបសងប្រាក់ថ្លៃការខូចខាតចំនួន ៥,០០០ (ប្រាំពាន់) បាតថៃ ក្នុងមួយថ្ងៃ លើការរឹបអូសយក អាប៊ុលសាស៊័រ ពណ៌លឿង ១គ្រឿង ម៉ាក KOMATSU SD25 ចាប់ពីថ្ងៃទី២២ ខែសីហា ឆ្នាំ២០២២ រហូតដល់ថ្ងៃប្រគល់អាប៊ុលសាស៊័រ វិញ ឱ្យទៅសហដើមចោទនៃបណ្តឹងតប និង៣, ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់សហចុងចម្លើយនៃបណ្តឹងតប។

ពាក្យបណ្តឹងតប៖ ការទាមទាររបស់សហដើមចោទនៃបណ្តឹតប សុំឱ្យតុលាការបង្គាប់ឱ្យខ្លួនសងប្រាក់បំណុលត្រឹមតែ ១២,៦៧៥$ (មួយម៉ឺនពីរពាន់ប្រាំមួយរយចិតសិប្រាំ) ដុល្លារអាមេរិក ឱ្យទៅចុងចម្លើយនៃបណ្តឹងតប ផ្អែកលើការគណនាតាមមាត្រា ៥៨៥ កថាខណ្ឌទី ៣ និងកថាខណ្ឌទី ៤ នៃក្រមរដ្ឋប្បវេណី ក៏ដូចជា ប្រកាសលេខៈ១២៨ កយ.



Scanned with CamScanner

ប្រក/១១ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ របស់ក្រសួងយុត្តិធម៌ ដើមចោទនៃបណ្តឹងអង្គសេចក្តី ដែលជាចុងចម្លើយនៃបណ្តឹងតបសុំបដិសេធ និងច្រានចោលនូវការទាមទារនេះ ដោយលើកយកទឡ្ហីករណ៍មកបញ្ជាក់ យោងអង្គហេតុត្រង់ចំណុច ១៣, ១៤ និងចំណុច ១៥ ខាងលើ។ ពាក្យបណ្តឹងតប៖ សហដើមចោទនៃបណ្តឹងតបសុំឱ្យតុលាការបង្គាប់ឱ្យចុងចម្លើយនៃបណ្តឹងតបសងប្រាក់ថ្លៃការខូចខាតចំនួន ៥,០០០ (ប្រាំពាន់) បាតថៃក្នុងមួយថ្ងៃ លើការរឹបអូសយកអាប៊ុលសាស័រពណ៌លឿង ១ គ្រឿងម៉ាក KOMATSU SD25 ចាប់ពីថ្ងៃទី០២ ខែសីហា ឆ្នាំ២០២២ រហូតដល់ថ្ងៃប្រគល់អាប៊ុលសាស័រវិញឱ្យទៅសហដើមចោទនៃបណ្តឹងតប។ ដើមចោទនៃបណ្តឹងអង្គសេចក្តី ដែលជាចុងចម្លើយនៃបណ្តឹងតបសុំបដិសេធ និងច្រានចោលនូវការទាមទារនេះ ដោយហេតុថាការរឹបអូសគ្រឿងចក្រនេះ ធ្វើឡើងតាមដីកាសម្រេចរក្សាការពារលេខ:៣០៣ គ.រ/២២ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០២២ ចេញដោយសាលាដំបូងខេត្តឧត្តរមានជ័យ ស្របតាមក្រមនីតិវិធីរដ្ឋប្បវេណី។

+លោកមេធាវី [redacted] ជាមេធាវីតំណាងដោយអាណត្តិឱ្យសហចុងចម្លើយ ឈ្មោះ [redacted] ឡុត ភេទប្រុស អាយុ ៥២ឆ្នាំ និងប្រពន្ធឈ្មោះ [redacted] សារ៉ាន ភេទស្រី អាយុ៤៣ឆ្នាំ បានថ្លែងការណ៍តបវិញថា ខ្លួនសូមធ្វើការថ្លែងការណ៍ចំពោះនីតិវិធីទាញហេតុផលដូចតទៅ ផ្អែកតាមកិច្ចសន្យាខ្ចីប្រាក់ថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០២២ និងកិច្ចសន្យាខ្ចីប្រាក់កាលពីថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២២ គឺធ្វើឡើងទាំងពីរលើក គឺជាកិច្ចសន្យាខ្ចីប្រាក់ ដែលកិច្ចសន្យាខ្ចីប្រាក់ គឺជាទំនាក់ទំនងគតិយុត្តិមួយរវាងដើមចោទ និងសហចុងចម្លើយ ប៉ុន្តែជាក់ស្តែងនៅក្នុងរឿងនេះ គឺគ្មានឯកសារប្រគល់សាច់ប្រាក់ទេពីដើមចោទ មកឱ្យសហចុងចម្លើយនោះទេ ដូច្នេះគ្មានអានុភាពអនុវត្តចំពោះសហចុងចម្លើយនោះឡើយ។ បើម្ចាស់បំណុលមិនទាន់ប្រគល់ប្រាក់ផង តើឱ្យកូនបំណុលត្រូវសងប្រាក់យ៉ាងដូចម្តេច? នៅក្នុងទំនាក់ទំនងគិតិយុត្តិ ម្ចាស់បំណុល មានកាតព្វកិច្ចត្រូវប្រគល់ប្រាក់ និងកូនបំណុលមានកាតព្វកិច្ចត្រូវសង តែនៅក្នុងអង្គហេតុនេះ គឺគ្មានការប្រគល់សាច់ប្រាក់នោះទេ។ នៅក្នុងអង្គហេតុការទាមទារនៅក្នុងបណ្តឹងអត់មានការលើកឡើងពីការលក់សិទ្ធិលើបំណុលនោះទេ គឺលើកឡើងតែខ្ចីប្រាក់តែប៉ុណ្ណោះ គឺកិច្ចសន្យាចំនួន ០៥ ខាងដើម គឺជាកិច្ចសន្យាខ្ចីបរិភោគតែប៉ុណ្ណោះ អត់មានការលើកឡើងពីការលក់សិទ្ធិលើបំណុលចំពោះសហចុងចម្លើយទេ ព្រោះដើមចោទមិនបានអនុវត្តសិទ្ធិប្រគល់ប្រាក់ទាំងពីរលើកចំនួន ៥០០០ (ប្រាំពាន់) ដុល្លារ និងចំនួន ១៥០០០ (មួយម៉ឺនប្រាំពាន់) ដុល្លារនោះទេ ដូច្នេះ សំណូមពរលោកចៅក្រម សម្រេចច្រានចោលការទាមទាររបស់ដើមចោទ។ ឈ្មោះ [redacted] សាវុន និងសហចុងចម្លើយមិនមានទំនាក់ទំនងគតិយុត្តជាមួយគ្នានោះទេ។ សូមបដិសេធការចំពោះការទាមទារត្រង់ចំណុចទី២ របស់សហដើមចោទដែលមាននៅក្នុងពាក្យបណ្តឹង ព្រោះអត់មានទំនាក់ទំនងគតិយុត្តិនោះទេ។ លុយដែលឱ្យសហកូនបំណុលដែលបានឱ្យខ្ចីដំបូងឡើយលុយរបស់ខ្លួន។ ថ្ងៃទី៣១ ខែមករា ខ្លួន បានប្រគល់តែចំនួន ១ (ម៉ឺន) ដុល្លារទេ សហកូនបំណុលជាពួកម៉ាកនឹងខ្លួន។ ខ្ចីលើកទី១ សហកូនបំណុលមកជួបខ្លួនផ្ទាល់។ ខ្ចីលើកទី២ សហកូនបំណុលជួបកូនរបស់ខ្លួន តែគាត់បានតេខលប្រាប់ថាសុំខ្ចីនឹងខ្លួនតាមទូរស័ព្ទដែរ ហើយខ្លួនផ្ញើ (វេ) លុយមកឱ្យកូនខ្លួនអ្នកកាន់កាប់គ្រប់គ្រង ព្រោះប្រពន្ធរបស់ខ្លួនគាត់នៅតែចំការ។ ខ្ចីលើកទី៣ គឺគាត់បានជួបខ្លួនតែតាមទូរស័ព្ទទេ ព្រោះគាត់មកយកលុយតែជាមួយកូនរបស់ខ្លួន។ ចំពោះលើកទី៤ និងលើកទី៥ ខ្លួនអត់បាននៅដែរ នៅតែកូនរបស់ខ្លួន គឺកូនបានបាញ់ឱ្យខ្លួនបានដឹងតាមតេលេក្រាម ថា សហកូនបំណុលបានខ្ចីពិតមែន។ ពេលផ្ទេរបំណុលទៅម្តាយធ្វើតែផ្ទាល់មាត់អត់បានធ្វើលាយលក្ខណ៍អក្សរទេ។ ខ្លួនសូមរក្សារចម្លើយដូចដែលខ្លួនបានថ្លែងការណ៍រួចហើយ។



Scanned with CamScanner

+លោកមេធាវី [redacted] ជាមេធាវីតំណាងដោយអាណ្ណិតឱ្យសហចុងចម្លើយឈ្មោះ [redacted] ឡុត ភេទប្រុស អាយុ ៥២ឆ្នាំ និងប្រពន្ធ ឈ្មោះ [redacted] សាវ៉ាន ភេទស្រី អាយុ៤៣ឆ្នាំ ជាដើមបណ្តឹងតប បានថ្លែងការណ៍លើបណ្តឹងតបថា ៖ ចំពោះកិច្ចសន្យាខ្ចីប្រាក់ គឺធ្វើឡើងដោយមានឈ្មោះ [redacted] លីហេង តែជាក់ស្តែងប្រាក់ជារបស់ឈ្មោះ [redacted] ស៊ីណាត ពិតប្រាកដ ខ្លួនសុំរក្សាចម្លើយដូចដែលសាក្សីឈ្មោះ [redacted] លីហេង បានធ្វើសេចក្តីថ្លែងការណ៍។ ខ្លួនសូមរក្សាការទាមទារដដែលដែលនៅក្នុងបណ្តឹងតប។ សូមរក្សាការទាមទារដូចមានក្នុងបណ្តឹងតបស្រាប់។

+សាក្សីឈ្មោះ [redacted] លីហេង ភេទប្រុស អាយុ២៤ឆ្នាំ បានធ្វើសេចក្តីថ្លែងការណ៍ថា ៖ ចំពោះលុយចំនួន ២ (ពីរ) ម៉ឺនដុល្លារ គឺជាលុយបំណុលចាស់ បានទារគាត់តែគាត់អត់មានលទ្ធភាពសង ដែលកូនបំណុលបានជំពាក់នៅក្នុងកិច្ចសន្យាចាស់។ ប៉ារបស់ខ្លួនឈ្មោះ [redacted] ស៊ីណាត ខ្វះលុយទិញឡាន ទារពីសហកូនបំណុលថា មិនទាន់មានថា ហើយសហកូនបំណុលនិយាយថា ឱ្យប៉ារខ្លួនរកខ្ចីអ្នកណាគេសិនក៏បាន ពេលនោះប៉ារបស់ខ្លួនបានទៅខ្ចីលុយម៉ាររបស់ខ្លួនឈ្មោះ [redacted] សាវុន ហើយក៏មានការផ្ទេរបំណុលដោយឱ្យសហកូនបំណុលឈ្មោះ [redacted] ឡុត និងឈ្មោះ [redacted] សាវ៉ាន់ សងបំណុលទៅឱ្យម៉ាររបស់ខ្លួនវិញ។ ពេលនោះសហកូនបំណុលគាត់យល់ព្រម ហើយកិច្ចសន្យាចាស់ក៏បាននិយាយគ្នាចប់អស់ហើយ ដោយព្រមព្រៀងគ្នាបង្កើតកិច្ចសន្យាថ្មីវិញ។ ម៉ាររបស់ខ្លួនឈ្មោះ [redacted] សាវុន គាត់បានប្រគល់លុយចំនួន ២ (ពីរ) ម៉ឺន ដុល្លារ ដើម្បីប៉ារបស់ខ្លួនយកលុយនោះទៅទិញឡាន។ ចំពោះកិច្ចសន្យាដំបូងសហកូនបំណុលខ្ចីលុយប៉ារបស់ខ្លួនចំពោះការខ្ចីលើកទី១ ហើយពេលទារការប្រាក់ គឺខ្លួនអ្នកខលទារ ។ សហចុងចម្លើយ ខ្ចីប្រាក់ចំនួន ៥ដង មានឈ្មោះ ប៉ាររបស់ខ្លួនចំនួន ១ នៅក្នុងកិច្ចសន្យាខ្ចីលើកដំបូង និងឈ្មោះខ្លួនចំនួន ០៤ កិច្ចសន្យាទៀត។ ខ្ចីប្រាក់៤ លើកចំនួន ២៥០០០ ដុល្លារ មានលុយខ្មែរចំនួន ២០ លានរៀល។ កិច្ចសន្យាយកការប្រាក់ពេលខ្លះ ៥% (លុយខ្មែរ) ចំពោះលុយដុល្លារ ៦% បានព្រមព្រៀងគ្នាត្រឹមត្រូវ ពេលខ្លះគាត់បង់យឺត។ ពេលគាត់សងប្រាក់ប៉ារបស់ខ្លួន ពេលប៉ាមិននៅ ពេលខ្លះខ្លួនអ្នកទទួលជំនួស ហើយបានចារនៅលើកិច្ចសន្យានោះទុកបញ្ជាក់។ គាត់បានសងប្រាក់ដើមចំនួន២០ លាន រៀល និងបានសងប្រាក់ដុល្លារទាំងអស់ចំនួន ១ (មួយ) ម៉ឺន ដុល្លារ។ ពាក់ព័ន្ធជាមួយម៉ាររបស់ខ្លួន គឺកិច្ចសន្យាបានព្រមព្រៀងប្តូរតែពីឈ្មោះ ខ្លួនទៅឈ្មោះ ម៉ាររបស់ខ្លួនឈ្មោះ [redacted] សាវុន តែម្តងដោយមានកិច្ចសន្យាខ្ចីប្រាក់ តែមិនបានធ្វើកិច្ចសន្យាផ្ទេរទេបំណុលនោះទេ អត់មានសាក្សីទេ។ គាត់បានសងការប្រាក់ចំនួន ១២ លានរៀល និងលុយដុល្លារខ្លួនអត់ចាំទេ អត់បានកត់ចំណាំទុក ដោយសារមិនដែលមានបញ្ហារឿងការប្រាក់។

+សាក្សីឈ្មោះ [redacted] ស៊ីណាត ភេទប្រុស អាយុ៥៣ឆ្នាំ បានធ្វើសេចក្តីថ្លែងការណ៍ថា ៖ រឿងលុយ ឈ្មោះ [redacted] ឡុត ជំពាក់ខ្លួន ៣ (ម៉ឺន) ដុល្លារ តែលុយខ្លួន តែ១ម៉ឺន ដុល្លារទេ ក្រោយមកសហកូនបំណុលបានមកខ្ចីខ្លួនទៀត ពេលនោះខ្លួនរវល់ផង ក៏ដាក់ឈ្មោះ កូនរបស់ខ្លួនវិញ។ លុយដែលជំពាក់គឺ សរុប៣ (ម៉ឺន) ដុល្លារ និងលុយខ្មែរ ចំនួន ២០ លានរៀល ។ ពេលត្រូវការលុយទារពីសហកូនបំណុលតែ គាត់អត់មានគាត់ថា រកខ្ចីកន្លែងណាសិនក៏បាន ពេលនោះទើបខ្លួនក៏ខ្ចីលុយម្តាយរបស់ខ្លួនឈ្មោះ [redacted] សាវុន ទើបព្រមព្រៀងគ្នាដោយមានផ្តិតស្នាមមេដៃត្រឹមត្រូវដោយឱ្យសហកូនបំណុលសងលុយដែលគាត់បានជំពាក់នោះទៅម្តាយរបស់ខ្លួនវិញ ជាការប្តូរម្ចាស់បំណុលពីខ្លួន និងកូនឈ្មោះ [redacted] លីហេង ទៅម្តាយរបស់ខ្លួនឈ្មោះ [redacted] សាវុន វិញ។ ខ្លួនបានទទួលលុយពីម្តាយខ្លួនចំនួន ២ (ម៉ឺន) ដុល្លារពិតមែន ហើយទាល់តែគាត់សងទើបបានយកទៅកក់ឡានគេ។ ឡានតម្លៃ ២៥០០០ ដុល្លារ។ លុយដែលឱ្យសហកូនបំណុលដែលបានឱ្យខ្ចីដំបូងឡើយលុយរបស់ខ្លួន។ ថ្ងៃទី៣១ ខែមករា ខ្លួន បានប្រគល់តែចំនួន ១ (ម៉ឺន) ដុល្លារទេ សហកូនបំណុលជាពួកម៉ាកនឹងខ្លួន។

ខ្ចីលើកទី១ សហកូនបំណុលមកជួបខ្លួនផ្ទាល់។ ខ្ចីលើកទី២ សហកូនបំណុលជួបកូនរបស់ខ្លួន តែគាត់បានតេខលប្រាប់ថាសុំខ្ចីនឹងខ្លួនតាមទូរស័ព្ទដែរ ហើយខ្លួនផ្ញើ (វេ) លុយមកឱ្យកូនខ្លួនអ្នកកាន់កាប់គ្រប់គ្រង ព្រោះប្រពន្ធរបស់ខ្លួនគាត់នៅតែចំការ។ ខ្ចីលើកទី៣ គឺគាត់បានជួបខ្លួនតែតាមទូរស័ព្ទទេ ព្រោះគាត់មកយកលុយតែជាមួយកូនរបស់ខ្លួន។ ចំពោះលើកទី៤ និងលើកទី៥ ខ្លួនអត់បាននៅដែរ នៅតែកូនរបស់ខ្លួន គឺកូនបានបាញ់ឱ្យខ្លួនបានដឹងតាមតេលេក្រាម ថា សហកូនបំណុលបានខ្ចីពិតមែន។ ពេលផ្ទេរបំណុលទៅម្ដាយធ្វើតែផ្ទាល់មាត់អត់បានធ្វើលាយលក្ខណ៍អក្សរទេ។ កិច្ចសន្យាខ្ចីទាំង ៤ លើក គឺគាត់មកយកលុយតែពីកូនរបស់ខ្លួនពិតប្រាកដមែន។

## សំអាងហេតុ

-ការទាមទារប្រាក់ដើមចំនួន ២០.០០០ (ពីរម៉ឺន) ដុល្លារអាមេរិក និងការប្រាក់១៨% ក្នុង០១ ឆ្នាំ របស់ដើមចោទ ផ្អែកលើកិច្ចសន្យាខ្ចីប្រាក់ និងបានផ្ដិតមេដៃលើកិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី០៨,៣០ ខែឧសភា ឆ្នាំ២០២២ រវាងឈ្មោះ [redacted]ឡុត និងប្រពន្ធឈ្មោះ[redacted]សារ៉ាន់។

-នៅក្នុងកិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០២២ និងកិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ ២០២២ ឃើញថា ពិតមានការព្រមព្រៀងគ្នាបង្កើតកិច្ចសន្យាខ្ចីប្រាក់រវាងឈ្មោះ [redacted] សារ៉ុន ភេទស្រី អាយុ៧២ឆ្នាំ និងឈ្មោះ[redacted]ឡុត ភេទប្រុស អាយុ៥២ឆ្នាំ និងប្រពន្ធឈ្មោះ [redacted] សារ៉ាន់ ភេទស្រី អាយុ៤៣ឆ្នាំ ដោយខ្លឹមសារនៃកិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០២២ រវាងឈ្មោះ [redacted] ឡុត និងឈ្មោះ [redacted]សារ៉ាន់ បានខ្ចីប្រាក់ពីឈ្មោះ [redacted] សារ៉ុន ចំនួន ៥០០០ $ (ប្រាំពាន់) ដុល្លារអាមេរិក អត្រាការប្រាក់ ២៥០ $ (ពីររយហាសិប) ដុល្លារអាមេរិក ក្នុង០១ ខែ កិច្ចសន្យាដែលនេះបញ្ជាក់ថា បើម្ចាស់លុយត្រូវការលុយត្រឡប់មកវិញ ត្រូវប្រាប់កូនបំណុលមុនរយៈពេល ០១ (មួយ) ខែ និងកិច្ចសន្យាខ្ចីប្រាក់ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២២ រវាងឈ្មោះ [redacted]ឡុត និងឈ្មោះ [redacted] សារ៉ាន់ បានខ្ចីប្រាក់ឈ្មោះ [redacted] សារ៉ុន ចំនួន ១៥,០០០ $ (មួយម៉ឺនប្រាំពាន់) ដុល្លារអាមេរិក អត្រាការប្រាក់ ៩០០ $ (ប្រាំបួនរយ) ដុល្លារអាមេរិក ក្នុង១ខែ កិច្ចសន្យាបញ្ជាក់ថា បើម្ចាស់លុយត្រូវការលុយត្រឡប់មកវិញ ត្រូវប្រាប់កូនបំណុលមុនរយៈពេល ០១ (មួយ) ខែ ដូចគ្នា ផ្អែកតាមការអះអាងរបស់ម្ចាស់បំណុល សាក្សី និងការពិនិត្យភស្តុតាងជាឯកសារនានា ឃើញថា ឈ្មោះ [redacted] ឡុត និងប្រពន្ធ ឈ្មោះ [redacted] សារ៉ាន់ ពិតជាមិនទាន់បានសងប្រាក់ទៅឱ្យឈ្មោះ [redacted] សារ៉ុន ដោយផ្អែកតាមកិច្ចសន្យាទាំងពីរខាងលើនេះពិតប្រាកដមែន។ គប្បីតុលាការទទួលស្គាល់ និងសម្រេចតាមការទាមទារនេះ។

-ចំពោះការទាមទារសំណងជម្ងឺចិត្ត ការខាតបង់ពេលវេលា ចំនួន ១៥.០០០.០០០ (ដប់ប្រាំ) លានរៀល របស់ដើមចោទ គប្បីតុលាការពិចារណា និងសម្រេច តាមទំហំនៃព្យសនកម្មជាក់ស្ដែង។

-ចំពោះពាក្យបណ្ដឹងតបចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២២ របស់សហដើមចោទនៃបណ្ដឹងតបឈ្មោះ [redacted] ឡុត ភេទប្រុស អាយុ៥២ឆ្នាំ និងប្រពន្ធឈ្មោះ [redacted] សារ៉ាន់ ភេទស្រី អាយុ៤៣ឆ្នាំ ដែលមានលោក [redacted] សុវណ្ណ ជាមេធាវីតំណាងដោយអាណត្តិ ដែលបានប្ដឹងឈ្មោះ[redacted]សារ៉ុន ភេទស្រី អាយុ៧២ឆ្នាំ ជាចុងចម្លើយនៃបណ្ដឹងតប ដែលមានលោក[redacted]ជាមេធាវីតំណាងដោយអាណត្តិ គឺពុំមានមូលហេតុគតិយុត្តិគ្រប់គ្រាន់ក្នុងការទាមទារនោះទេ ហេតុនេះ គប្បីតុលាការពិចារណា និងសម្រេចច្រានចោលការទាមទារនេះ។

-ចំពោះប្រាក់ប្រដាប់ក្ដី យោងតាមបញ្ញត្តិមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី គប្បីសម្រេចឱ្យចុងចម្លើយជាអ្នកទទួលបន្ទុក។



Scanned with CamScanner

# សេចក្តីសម្រេចបញ្ចប់

១.ច្រានចោលការទាមទារក្នុងពាក្យបណ្តឹងតប ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២២ របស់សហដើមចោទនៃបណ្តឹងតបឈ្មោះ [redacted] ឡុត ភេទប្រុស អាយុ៥២ឆ្នាំ និងប្រពន្ធឈ្មោះ [redacted] សារ៉ាន់ ភេទស្រី អាយុ៤៣ឆ្នាំ ដែលមានលោក [redacted]ាមេធាវីតំណាងដោយអាណត្តិ ទាំងស្រុង។

២.បង្គាប់ឱ្យសហចុងចម្លើយឈ្មោះ [redacted] ឡុត ភេទប្រុស អាយុ៥៣ឆ្នាំ និងប្រពន្ធឈ្មោះ [redacted] សារ៉ាន់ សងប្រាក់ដើមចំនួន ២០.០០០ (ពីរម៉ឺន) ដុល្លារអាមេរិក និងការប្រាក់ចំនួន ១៨% ក្នុង១ (មួយ) ឆ្នាំ មកឱ្យដើមចោទឈ្មោះ [redacted] សារុន ភេទស្រី អាយុ៧២ឆ្នាំ។

៣.បង្គាប់ឱ្យសហចុងចម្លើយឈ្មោះ [redacted] ឡុត ភេទប្រុស អាយុ៥៣ឆ្នាំ និងប្រពន្ធឈ្មោះ [redacted] សារ៉ាន់ រួមគ្នាសងសំណងជម្ងឺចិត្ត និងការខូតបង់ពេលវេលាចំនួន ២.០០០.០០០ (ពីរលាន) រៀល មកឱ្យដើមចោទឈ្មោះ [redacted] សារុន ភេទស្រី អាយុ៧២ឆ្នាំ។

៤.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់សហចុងចម្លើយ។

សាលក្រមនេះបានបញ្ចប់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី១១ ខែមករា ឆ្នាំ២០២៣ និងប្រកាសជាសាធារណៈនៅថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២៣។

ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

ថ្ងៃអង្គារ ២ រោច ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅឧត្តរមានជ័យ, ថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២៣

**ក្រឡាបញ្ជី**

**ចៅក្រម**

---

**បានឃើញ**

ធ្វើនៅឧត្តរមានជ័យ, ថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២៣

**ចៅក្រម**

[redacted]

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ធ្វើនៅឧត្តរមានជ័យ, ថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២៣

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner